**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:១០០..សសរ**

**សេចក្តីសម្រេច**
**ស្តីពី**
**ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិផែនការយុទ្ធសាស្ត្រ ស្ថិតិកសិកម្មនិងជនបទនៅព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឆាយ ថន** | ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| ២- ឯកឧត្តម | **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣- ឯកឧត្តម | **រិន ធីរៈ** | រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម | **កែវ រ៉េមី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៥- ឯកឧត្តម | **ផាន់ ផល្លា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៦- លោកជំទាវ | **អ៊ូ វ៉ាឌី** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិការ |
| ៧- ឯកឧត្តម | **សាមូ អូហ្សាណា** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- លោកជំទាវ | **សេង វណ្ណាសាយ** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិការ |
| ៩- ឯកឧត្តម | **សៅ ជីវ័ន្ត** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០- ឯកឧត្តម | **ហោ ដារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១១- ឯកឧត្តម | **ឡុយ ចំរើន** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១២- លោកជំទាវ | **ហង់ លីណា** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ | សមាជិការ |
| ១៣- លោក | **ឃិន សុវណ្ណលក្ខណ៍** | អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ | លេខាធិការ។ |

**ប្រការ២ .-**

គណៈកម្មាធិការជាតិផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូចតទៅ ៖

- ផ្តល់ការណែនាំនិងត្រួតពិនិត្យលើការរៀបចំផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទឱ្យស្របតាមគោលនយោបាយជាតិនិងអាទិភាពនៃកម្រិតអភិវឌ្ឍដោយទំនាក់ទំនងជាមួយគណៈកម្មការបច្ចេកទេសស្ថិតិកសិកម្មនិងជនបទ

- ធានាឱ្យប្រាកដថាផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅកម្ពុជាស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថិតិ (NSDS) ដែលអនុម័តដោយ Paris21
- ពិនិត្យឯកសារនិងរបាយការណ៍ឡើងវិញដែលរៀបចំដោយគណៈកម្មការបច្ចេកទេសស្ថិតិកសិកម្មនិងជនបទ
- អនុម័តនូវឯកសារនិងដំណើរការផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅកម្ពុជាសំខាន់ៗដូចជាផែនទីបង្ហាញផ្លូវ និងរបាយការណ៍វាយតម្លៃស៊ីជម្រៅរបស់គម្រោង ឯកសារផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅកម្ពុជាចុងក្រោយ និងផែនការការងារប្រចាំឆ្នាំក្នុងអំឡុងពេលអនុវត្ត
- ផ្តល់អនុសាសន៍ជូនដល់រាជរដ្ឋាភិបាលពីប្រភពថវិការបស់ដៃគូអភិវឌ្ឍ សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅព្រះរាជាណាចក្រកម្ពុជា
- ធានាឱ្យប្រាកដថាផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅព្រះរាជាណាចក្រកម្ពុជាបានដាក់បញ្ចូលនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថិតិ(NSDS)
- ធ្វើការវាយតម្លៃនិងតាមដានគម្រោងពាក់កណ្តាលអាណត្តិនិងបញ្ចប់គម្រោងផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទ និងចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅព្រះរាជាណាចក្រកម្ពុជាដំណាក់កាលបន្ទាប់
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជាតាមរយៈទីស្តីការ-គណៈរដ្ឋមន្ត្រី
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់ប្រធានគណៈកម្មាធិការជាតិ។

**ប្រការ៣ .-**

ប្រធានគណៈកម្មាធិការជាតិផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិបង្កើតគណៈកម្មការបច្ចេកទេស និងលេខាធិការដ្ឋានជាជំនួយការក្នុងការអនុវត្តតួនាទីភារកិច្ច។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការបច្ចេកទេសនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

**ប្រការ៤ .-**

គណៈកម្មាធិការជាតិផែនការយុទ្ធសាស្ត្រស្ថិតិកសិកម្មនិងជនបទនៅព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ